# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ: ១១០/២៥ ក.ប/ប្រ.ក.ស.ធ.ក

# ប្រកាស
## ស្តីពី
## សេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាស គ្រឹះស្ថាន
## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

### ប្រការ១ .-

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវរៀបចំស្នើសុំសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅមុនពេលបើកសហគ្រាស គ្រឹះស្ថានជាស្ថាពរ។

### ប្រការ២ .-

ការស្នើសុំចុះបញ្ជិកាសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើឡើងតាមការកំណត់ដូចខាងក្រោម៖

១-ចំពោះសហគ្រាស គ្រឹះស្ថាន ដែលទើបនឹងបើកដំណើរការថ្មី ត្រូវស្នើសុំចុះបញ្ជិកាសេចក្តីប្រកាសជូន



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ដំណឹងបើកសហគ្រាស គ្រឹះស្ថានតាមការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយត្រូវបំពេញព័ត៌មាន និងបញ្ចូលឯកសារភ្ជាប់តាមលក្ខខណ្ឌតម្រូវទាំងអស់ក្នុងទម្រង់អេឡិចត្រូនិក ដែលកំណត់ក្នុងគេហទំព័រចុះបញ្ជី https://registrationservices.gov.kh។ ក្រោយពីទទួលបានបញ្ជិកាសេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថាន ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវបន្តចុះឈ្មោះបង្កើតគណនីសហគ្រាស គ្រឹះស្ថានចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (Labour Centralized Management System-LACMS) តាមរយៈគេហទំព័រ https://lacms.mlvt.gov.kh ដើម្បីអនុវត្តកាតព្វកិច្ចផ្សេងទៀតស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ។

២-ចំពោះសហគ្រាស គ្រឹះស្ថាន ដែលកំពុងដំណើរការអាជីវកម្ម និងមិនទាន់បានចុះបញ្ជិកាសេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានក្នុងទម្រង់អេឡិចត្រូនិក ត្រូវចុះឈ្មោះបង្កើតគណនីសហគ្រាស គ្រឹះស្ថានចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (Labour Centralized Management System-LACMS) តាមរយៈគេហទំព័រ https://lacms.mlvt.gov.kh ដើម្បីអនុវត្តកាតព្វកិច្ចផ្សេងទៀតស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីប្រកាសនេះចូលជាធរមាន។

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវដាក់តាំងសេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាដូចមានគំរូក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ នៅក្នុងទីចាត់ការរបស់សហគ្រាស គ្រឹះស្ថាន។

**ប្រការ៣ .-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលបានកំណត់ក្នុងប្រការ១ ខាងលើ ត្រូវជូនដំណឹងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃមានការផ្លាស់ប្ដូរ ឬបន្ទាប់ពីថ្ងៃដែលបញ្ឈប់សកម្មភាពអាជីវកម្ម ដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស គ្រឹះស្ថាន ក្នុងករណីមានការផ្លាស់ប្ដូរព័ត៌មានណាមួយក្នុងចំណោមព័ត៌មានដូចខាងក្រោម៖

- នាមករណ៍សហគ្រាស គ្រឹះស្ថាន
- ម្ចាស់ ឬអ្នកតំណាង នាយកសហគ្រាស គ្រឹះស្ថាន
- ការផ្ទេរ ឬការផ្លាស់ប្ដូរម្ចាស់ភាគហ៊ុន ព័ត៌មានលម្អិតអភិបាល ឬការតម្កល់លក្ខន្តិកៈថ្មី
- អាសយដ្ឋាន
- ទ្រង់ទ្រាយសហគ្រាស គ្រឹះស្ថាន
- កម្មវត្ថុ ឬសកម្មភាពអាជីវកម្ម
- លេខអត្តសញ្ញាណកម្មសារពើពន្ធ ឬការធ្វើបច្ចុប្បន្នភាពប័ណ្ណពន្ធប៉ាតង់ថ្មី
- ការផ្អាកអាជីវកម្ម
- ការបញ្ឈប់អាជីវកម្មជាស្ថាពរ
- ប្រធានរដ្ឋបាល អ្នកទទួលបន្ទុកផ្នែកធនធានមនុស្ស ឬអ្នកទទួលបន្ទុកផ្នែកអនុលោមភាពការងារ
- ព័ត៌មានគណនីធនាគារ
- ព័ត៌មានទំនាក់ទំនង លេខទូរសព្ទ សារអេឡិចត្រូនិក ឬអ្នកប្រើប្រាស់ប្រព័ន្ធ
- ព័ត៌មានទូទៅផ្សេងទៀតរបស់សហគ្រាស គ្រឹះស្ថាន មានជាអាទិ៍ ចំនួនកម្មករនិយោជិត ផលិតផលចម្បង ផលិតផលម៉ាក ព័ត៌មានការបញ្ជាទិញ ការនាំចូលវត្ថុធាតុដើម និងការនាំចេញរបស់សហគ្រាស គ្រឹះស្ថាន។

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលមានការផ្លាស់ប្ដូរព័ត៌មានណាមួយ ដូចមានកំណត់ក្នុងកថាខណ្ឌទី១ ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មាន ដោយត្រូវបំពេញព័ត៌មាន និងភ្ជាប់ឯកសារតម្រូវនៃការផ្លាស់ប្ដូរព័ត៌មានទាំងនោះ។

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវរៀបចំលេខទូរសព្ទទំនាក់ទំនងផ្ទាល់ និងសារអេឡិចត្រូនិកប្រចាំសហគ្រាស គ្រឹះស្ថាន ព្រមទាំងផ្តល់លេខទូរសព្ទទំនាក់ទំនងក្នុងមុខងាររបស់ប្រធានរដ្ឋបាល និងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវព័ត៌មានរបស់អ្នកទទួលបន្ទុកទំនាក់ទំនងប្រចាំសហគ្រាស គ្រឹះស្ថាន។

តាមការចាំបាច់ ឬនៅពេលដែលអធិការការងារពិនិត្យឃើញថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានបានប្រើប្រាស់ព័ត៌មានមិនពិត ឬមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ ឬមិនច្បាស់លាស់ ឬឯកសារក្លែងក្លាយ អធិការការងារអាចអញ្ជើញម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានមកផ្តល់ព័ត៌មានបន្ថែម ឬមកធ្វើបច្ចុប្បន្នភាព។

**ប្រការ៤ .-**

អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងការផាកពិន័យ ឬផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ។

**ប្រការ៥ .-**

ប្រកាសលេខ ២៨៨ សកបយ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីសេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាស គ្រឹះស្ថាន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៦ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៥កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ២២០/២៥ ក.ប/ប្រ.ក.អ.ធ.ក ចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ២០២៥
ស្តីពីសេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាស គ្រឹះស្ថាន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
MINISTRY OF LABOUR AND VOCATIONAL TRAINING
លេខចុះបញ្ជិកា/Nº៖ DE.......................... អជក

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

## សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស

**១. នាមករណ៍សហគ្រាស** ៖ ..................................................
**២. កាលបរិច្ឆេទនៃការបើក** ៖ ថ្ងៃទី...................... ខែ...................... ឆ្នាំ...................
**៣. លេខអត្តសញ្ញាណកម្មសារពើពន្ធ** ៖ ..................................................
**៤. អាសយដ្ឋានសហគ្រាស** ៖ ផ្ទះលេខ....... ផ្លូវ........... ភូមិ.............. ឃុំ/សង្កាត់ ..................
ក្រុង/ស្រុក/ខណ្ឌ.......... រាជធានី/ខេត្ត............... លេខទូរសព្ទ ៖ ......................
អ៊ីមែល ៖ ..................................................

**- នាមម្ចាស់សហគ្រាស** ៖ .................................. សញ្ជាតិ.........................
**- នាមនាយកសហគ្រាស** ៖ .................................. សញ្ជាតិ.........................

**៥. ទម្រង់ទ្រាយសហគ្រាស** ៖ ..................................................
**៦. សកម្មភាពអាជីវកម្ម** ៖ ..................................................
**៧. អាសយដ្ឋានសាខាសហគ្រាស** ៖ ផ្ទះលេខ....... ផ្លូវ....... ភូមិ............... ឃុំ/សង្កាត់ ..................
ក្រុង/ស្រុក/ខណ្ឌ.......... រាជធានី/ខេត្ត............... លេខទូរសព្ទ ៖ ......................
អ៊ីមែល ៖ ..................................................

**៨. ចំនួនកម្មករនិយោជិតប៉ាន់ស្មានសរុប** ៖ ...............នាក់ (ស្រី........នាក់) ក្នុងនោះជនបរទេស : ............នាក់ (ស្រី.......នាក់)
**៩. ប្រភេទគ្រឿងចក្រ និងវិធីប្រើសម្ភារ វត្ថុធាតុដើមប្រកបដោយគ្រោះថ្នាក់** ៖ មាន/គ្មាន
**១០. ចំនួនម៉ោងធ្វើការក្នុងមួយថ្ងៃ ឬមួយសប្តាហ៍** ៖ .........................ម៉ោង/ថ្ងៃ ឬ...........................ម៉ោង/សប្តាហ៍

## Declaration of Opening the Enterprise

-Enterprise's Name: ..................................................
-Incorporation Date: ..................................................
-Tax Identification Number (TIN): ..................................................
-Telephone:.......................................... E-mail: ..................................
-Owner's Name:.......................................... Nationality: ..................................
-Director's Name:.......................................... Nationality: ..................................
-Form of Enterprise: ..................................................
-Business Activities: ..................................................
-Telephone:.......................................... E-mail: ..................................
-Number of Estimated Employees: ..................................................(Female: ...................)
-Number of Foreign Employees: ..................................................(Female: ...................)
-Kind of Dangerous Machinery and Facilities: .................................. (Yes/No) ..................................
-Number of Working Hours Per day or Per Week:.................................. hours/day or ..................................hours/week

...................... ថ្ងៃទី.......... ខែ............... ឆ្នាំ.....
...................... Date........ Month.............. Year.....

**ត.ប. រដ្ឋមន្ត្រី**
R. Minister
**អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ**
Director General of General Department of Labour

**QR Code**